ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច
TRUST REGULATOR

និយ័តករបរធនបាលកិច្ច
លេខ: ០០២១/២៣.និ.ប.ធ./ស.ជ.ប

# សេចក្តីជូនដំណឹង
# ស្តីពី
# ការទទួលចុះឈ្មោះចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី២ ឆ្នាំ២០២៣

និយ័តករបរធនបាលកិច្ច (**និ.ប.ធ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចសម្រាប់ក្រុមហ៊ុនបរធនបាល, ក្រុមហ៊ុនបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក(Escrow Services) ក្នុងវិស័យបរធនបាលកិច្ច, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាទុក ឬសេវារក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច, និងសាធារណជនទាំងអស់មេត្តាជ្រាបថា÷ **និ.ប.ធ.** នឹងចាប់ផ្តើមទទួលពាក្យចុះឈ្មោះចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី២ ឆ្នាំ២០២៣ ចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣។ អាស្រ័យហេតុនេះ បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចទាំងអស់ សូមអញ្ជើញមកចុះឈ្មោះ និងបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលនេះ នៅនិយ័តករបរធនបាលកិច្ច ដែលមានទីតាំងនៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាន់ទី៨ អាសយដ្ឋានផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទតេលេក្រាម ០៩២ ១៩៣ ៩៧៦/ ០៧៧ ២៧៨ ០១៩ ឬអ៊ីមែល÷ info@trustregulator.gov.kh។

**បញ្ជាក់÷** ចំពោះវគ្គបណ្តុះបណ្តាល និងការប្រឡងបុគ្គលសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិនេះ ត្រូវបង់ថ្លៃចូលរួមចំនួន ៨០០,០០០៛ (ប្រាំបីរយពាន់រៀល) ក្នុងមួយនាក់។ ចំពោះពាក្យស្នើសុំសូមទាញយកតាមរយៈតំណរមួយនេះ https://drive.google.com/drive/folders/1qof-OnfBzY7jXYwYQJQROpSLz2d2aYtE ឬ តាមរយៈ QR Code ខាងក្រោម។

**សម្គាល់÷** ចំពោះកាលបរិច្ឆេទក្នុងការរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យនបរធនបាលកិច្ច លើកទី២ ឆ្នាំ២០២៣ **និ.ប.ធ.** នឹងជម្រាបជូននៅពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន និងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៤ ១៧ ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២៣
**និយ័តករបរធនបាលកិច្ច**

សូមទាញយកពាក្យ
ស្នើសុំនៅទីនេះ!

អាសយដ្ឋាន : អគារ ១៦៨F (ជាន់ទី៨) សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Kingdom of Cambodia
ទូរសព្ទ : (+៨៥៥)២៣-២៣៧-៨៨៨
សារអេឡិចត្រូនិច : info@trustregulator.gov.kh
គេហទំព័រ : www.trustregulator.gov.kh